

# វគ្គបណ្តុះបណ្តាល ទី១ ស្តីអំពីយេនឌ័រ

## សេចក្តីផ្តើមអំពីវិធីសាស្រ្តផ្នែកយេនឌ័រ៖ បញ្ញត្តិ និងគោលការណ៍ណែនាំមូលដ្ឋាន

MINISTERIO DE ASUNTOS EXTERIORES Y DE COOPERACIÓN

aecid

Gender Consultancy Creative Development

Open Institute

# ការរំពឹងទុក

1. សកម្មភាពឬសភាពនៃការរំពឹងទុកឬសភាពដែលត្រូវបានរំពឹងទុក

2. *(តាមធម្មតាមានច្រើន)* អ្វីមួយដែលត្រូវបានសម្លឹងទៅរកមិនថាជាការខ្លាចបារម្ភ ឬជាក្តីសង្ឃឹមធំៗដែលគេមានសម្រាប់អនាគតរបស់គេ ឬការរំពឹងទុកអាក្រក់បំផុតរបស់ពួកគេ។

3. ឥរិយាបទនៃការរំពឹងទុក ឬឥរិយាបទនៃការសង្ឃឹមជាមុនការគិតទុកជាមុនអំពីអ្វីមួយ។

# តើពេលនេះយើងមានក្តីរំពឹងទុកអ្វីខ្លះអំពីវគ្គបណ្តុះបណ្តាលនេះ?

...ការរំពឹងទុកល្អៗ និងការរំពឹងទុកអាក្រក់ៗ





# តើយើងរំពឹងចង់បានអ្វីពីការបណ្តុះបណ្តាលបែបនេះ?... ហើយតើយើងខ្លាចអ្វីខ្លះ?




វិទ្យាស្ថានបើកទូលាយ
Open Institute

# សូមចងចាំថាអ្នកត្រូវឆ្លុះបញ្ចាំងលើ៖

- តើការរៀនសូត្រនៅក្នុងវគ្គបណ្តុះបណ្តាលនេះអាចជះឥទ្ធិពលលើឥរិយាបទនិងជំនឿរបស់អ្នកផ្ទាល់ដោយរបៀបណា?

- តើយើងអាចធ្វើអ្វីបានខ្លះ នៅកម្រិតផ្ទាល់ខ្លួន និងកម្រិតវិជ្ជាជីវៈ ដើម្បីលើកកំពស់សមភាពយេនឌ័រ?



ជាការពិតណាស់ ពួកយើងភាគច្រើនមកទីនេះព្រោះយើងជឿជាក់ថាយើង ត្រូវការយល់ឲ្យកាន់តែច្បាស់ថែមទៀតអំពីអត្ថន័យរបស់យេនឌ័រដើម្បីឲ្យយើងអាចធ្វើការមួយចំនួននៅក្នុងការងារបច្ចុប្បន្ននិងការងារនាពេលអនាគតរបស់ យើង។ ហេតុនេះសំនួរសំខាន់ៗដែលត្រូវសួរមាន....

# … ហេតុអ្វីបានជាត្រូវសិក្សាអំពីយេនឌ័រ? ឬបើនិយាយឲ្យចំទៅ…

- តើហេតុអ្វីបានជាយើងគួរបញ្ចូលសព្ទ**យេនឌ័រ**ទៅក្នុងវិធីដែលយើងពិនិត្យមើលទៅក្នុងតថភាពសង្គម?

- តើបញ្ហាយេនឌ័រមានទំនាក់ទំនងអ្វីជាមួយជីវិតផ្ទាល់ខ្លួន/បទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ?

បើនិយាយឲ្យចំទៅ វគ្គបណ្តុះបណ្តាលក្រោមចំណងជើងថា សេចក្តីផ្តើមស្តីអំពីវិធីសាស្ត្រផ្នែកយេនឌ័រ៖ បញ្ញត្តិ និងគោលការណ៍ណែនាំមូលដ្ឋាន របស់យើងនេះ មានបំណងសម្រេចឲ្យបាននូវវត្ថុបំណងខាងក្រោម

១

ដើម្បីពន្យល់អំពីសមាសធាតុផ្នែកសង្គមដែលបង្កឲ្យមានវិសមភាពរវាងស្ត្រី និងបុរស

២

ដើម្បីធ្វើបទបង្ហាញអំពីបញ្ញត្តិ និងខ្លឹមសារ
នានា ដែលយើងត្រូវការ ដើម្បីលុបបំបាត់នូវ
ការរើសអើង ដើម្បីកសាងសមភាពយេនឌ័រ
ដោយឈរលើទស្សនវិស័យសមធម៌

# មានបញ្ញត្តិ ឬគំនិតជាច្រើនដែលមនុស្សឬ គ្រប់គ្នាច្រើនតែលើកឡើងនៅពេលយើង និយាយអំពីយេនឌ័រ



# បញ្ញត្តិសំខាន់ៗ

- ភេទ/យេនឌ័រ
- តួនាទី និងផ្នត់គំនិតសង្គម
- បំណែងចែកពលកម្មទៅតាមភេទ
- សមភាព/សមធម៌
- លក្ខខណ្ឌ/ជំណែង
- សេចក្តីត្រូវការ និងផលប្រយោជន៍ចំពោះមុខ និងជាយុទ្ធសាស្ត្រ
- ការបញ្ជ្រាប និងការផ្តល់អំណាច

# ឥឡូវសូមពិនិត្យមើលថាតើមានការរំពឹងទុកអ្វីខ្លះដែលទាក់ទងនឹងបញ្ញត្តិទាំងអស់នេះ?



# តើរូបរាងកាយនិយាយ ដូចម្តេច...?

# ភេទ

ភាពខុសគ្នាផ្នែកជីវសាស្រ្តរវាងស្រ្តី និងបុរស ដែលមានលក្ខណៈជាសាកល ជាក់ច្បាស់ ហើយជាទូទៅមានលក្ខណៈជាអចិន្ត្រៃ។

# ទារកកើតមក...ជាប្រុស ឬជាស្រី?

នៅពេលយើងកើតមកភ្លាម **វត្ថុដំបូងបំផុត** ដែលកំណត់អត្តសញ្ញាណរបស់យើង គឺអវៈយវៈភេទរបស់យើង...

**ហើយក្នុងនោះមានការរំពឹងទុកពីមុន និងការរំពឹងទុកបច្ចុប្បន្នអំពីអវៈយវៈភេទទាំងនោះ...**




សាច់ញាតិរបស់យើងច្បាស់ជាទិញសម្លៀកបំពាក់ដែលពួកគេគិតថាសមស្របជាមួយភេទរបស់យើង ហើយចាប់ផ្តើមគិតអំពីអនាគតរបស់យើង...

# ករណីផ្ទាល់ខ្លួនរបស់ខ្ញុំគឺជាបញ្ហាសង្គម...



តាំងពីយើងកើតមក ញាណស្តីពីជីវិត
របស់យើងត្រូវបានបង្កើតឡើង។
ប្រសិនបើយើងជាស្រី គេចាប់ផ្តើមឲ្យ
តុក្កតាកូនក្រមុំមកយើងលេង ហើយ
បន្តិចម្តងៗ យើងចាប់ផ្តើមរៀនធ្វើ
ការងារដូចជាបោសផ្ទះ ជូតផ្ទះ លាង
ចាន រៀបចំម្ហូបឲ្យឪពុកជាដើម។

. ប្រសិនបើយើងជាប្រុស យើងច្បាស់ជាមានកូនឡាន បាល់ ហើយបន្តិម្តងៗ យើងរៀនទៅស្រែជាមួយឪពុក ដើម្បីជួយធ្វើការងារគាត់ ហើយក្រោយមកយើងក៏ស្រាប់តែចេះទៅកន្លែងផឹកស៊ីៗ



*ជាការពិតណាស់ នេះមិនមែនជារូបភាពជាក់ស្តែងនៃអត្តសញ្ញាណរបស់មនុស្សទាំងអស់នោះឡើយ....*



ប៉ុន្តែអ្វីដែលសំខាន់នោះគឺថា **ភាពខុសគ្នានៅក្នុងលក្ខណៈសម្បត្តិផ្នែករាងកាយ** មាន**តម្លៃ** ដែលកំណត់ដោយក្រុមសង្គម ចាប់តាំងពីពេលដំបូងបំផុតដែលគេដឹងថាភេទរបស់យើងគឺជា ប្រុស ឬជាស្រីមកម្លេះ។

# ទំនាក់ទំនងរវាងយេនឌ័រនិងភេទ

មនុស្សម្នាក់ៗមាន**ភេទយេនឌ័រនិងអត្តសញ្ញាណផ្នែកយេនឌ័រ**។ ទាំងអស់នេះគឺជាទិដ្ឋភាពផ្នែកភេទរបស់យើង។ ទិដ្ឋភាពទាំងអស់នេះគឺស្តីអំពីថាតើខ្លួនយើងជានរណាហើយទិដ្ឋភាពទាំងអស់នេះសុទ្ធតែខុសៗគ្នាប៉ុន្តែទាក់ទងគ្នា។

## ប៉ុន្តែ...

**ភេទគឺជាលក្ខណៈផ្នែកជីវសាស្ត្រ**។ លក្ខណៈទាំងអស់នេះរួមមានសមាសធាតុផ្នែកសេនេទិចអ័រម៉ូននិងផ្នែកនានានៃរាងកាយរបស់យើងរួមទាំងសរីរាង្គភេទនិងសរីរាង្គបន្តពូជរបស់យើងផងដែរ។

# ចំណែកយេនឌ័រ...

- **សំ**ដៅទៅលើការរំពឹងទុករបស់សង្គមអំពីរបៀបដែលយើងគួរគិត និងគួរធ្វើសកម្មភាពក្នុងនាមជាកុមារីនិងកុមារាស្ត្រីនិងបុរស។ នេះគឺជា ឋានៈផ្នែកជីវសាស្ត្រសង្គមនិងច្បាប់របស់យើងក្នុងនាមជាស្ត្រីនិងបុរស។
- **គឺ**ជាតួនាទី និងការទទួលខុសត្រូវដែលសង្គមបង្កើតឡើងដែលប្រគល់ទៅឲ្យស្ត្រីនិងបុរសនៅក្នុងសង្គម ឬទីកន្លែងជាក់លាក់ណាមួយព្រមទាំងរចនាសម្ព័ន្ធសង្គមដែលគាំទ្រឲ្យមានតួនាទីនិងការទទួលខុសត្រូវទាំងអស់នោះ។



**អត្តសញ្ញាណផ្នែកយេនឌ័រ**គឺរបៀបដែលយើងមានអារម្មណ៍ និង
បង្ហាញចេញមកនូវយេនឌ័រនិងតួនាទីយេនឌ័ររបស់យើងរួមមាន
តាំងពីសម្លៀកបំពាក់ អាកប្បកិរិយានិងរូបរាងផ្ទាល់ខ្លួន។ នេះគឺជា
អារម្មណ៍ដែលយើងចាប់មានតាំងពីយើងនៅតូចអាយុពីរ ឬបីឆ្នាំ
មកម្លេះ។

# មនុស្សប្តូរភេទ




មនុស្សមួយចំនួនយល់ឃើញថាអត្តសញ្ញាណផ្នែកយេនឌ័ររបស់ខ្លួនមិនស្របគ្នាជាមួយភេទជីវសាស្ត្ររបស់ខ្លួន។ នៅពេលមានរឿងបែបនេះកើតឡើងគេកំណត់អត្តសញ្ញាណមនុស្សប្រភេទនេះថាជាមនុស្សប្តូរភេទ។

# ការកំណត់ទាំងអស់នេះជះឥទ្ធិពលដល់របៀបដែលយើងរស់នៅក្នុងនាមជាមនុស្សស្រីនិងមនុស្សប្រុសតាំងពីយើងនេះជាកុមារ...





# ប៉ុន្តែជាក់ស្តែង បើនិយាយអំពីរាងកាយរបស់យើង...




ទាក់ទងនឹងចំណុចនេះនិយមន័យរបស់អង្គការសុខភាពពិភពលោកដែលយើងបានដកស្រង់នៅវគ្គខាងដើមបាននិយាយដូចខាងក្រោម៖

*. ឧទាហរណ៍មួយចំនួនអំពីលក្ខណៈសម្បត្តិផ្នែកភេទ៖*

- មនុស្សស្រីអាចមានរដូវប៉ុន្តែមនុស្សប្រុសមិនអាចមានរដូវទេ។
- មនុស្សប្រុសមានពងស្វាស ប៉ុន្តែមនុស្សស្រីមិនមានពងស្វាសទេ។
- មនុស្សស្ត្រីមានដើមទ្រូងលូតលាស់ដែលតាមធម្មតាតែងមានសមត្ថភាពក្នុងការបញ្ចេញទឹកដោះ (ផលិតទឹកដោះ) ឯមនុស្សប្រុសមិនមានដើមទ្រូងបែបនេះទេ។
- តាមធម្មតា មនុស្សប្រុសមានឆ្អឹងធំជាងមនុស្សស្រី។

# តើសង្គមនិយាយដូចម្តេចខ្លះអំពីរាងកាយរបស់យើង...

## ការបកស្រាយផ្នែកសង្គមនិងផ្នែកច្បាប់អំពីរាងកាយរបស់ស្ត្រី

- ការប្រើប្រាស់សម្លៀកបំពាក់ purdha
- ការចៀរប្រដាប់ភេទ
- ការចងរុំបន្ថយទំហំជើង



# ឧទាហរណ៍មួយទៀតអំពីការការកំណត់របស់សង្គមទៅលើភេទ...

- នៅប្រភេទភាគច្រើនស្ត្រីរកចំណូលបានតិចជាបុរសយ៉ាងខ្លាំង លើការងារដូចគ្នា

- នៅប្រទេសវៀតណាម ឬ**កម្ពុជា** មានបុរសច្រើនជាងស្ត្រី ដែលជក់បារី ព្រោះការជក់បារី មិនត្រូវបានចាត់ទុកថាជារឿងសមស្របទៅតាមប្រពៃណីនោះទេ។ រឿងការផឹកស្រា ក៏ដូចគ្នានេះដែរ។

- នៅប្រទេស អារ៉ាប៊ី សាអូឌី គេអនុញ្ញាតឲ្យបុរសបើករថយន្ត តែគេមិនអនុញ្ញាតឲ្យស្ត្រីបើករថយន្តទេ។

# ភេទ និងយេនឌ័រ

| ភេទ | ការរំពឹងទុក | យេនឌ័រ |
| --- | --- | --- |
| ជីវសាស្រ្ត | | សង្គមបង្កើតឡើង |
| មានមកពីកំណើត | | មិនមែនមកពីកំណើត |
| មិនមានការផ្លាស់ប្តូរ | | អាចផ្លាស់ប្តូរបាន |

ភេទ/មានតែមនុស្សស្រីប៉ុណ្ណោះដែលអាចបង្កើតកូនបាន/មានតែមនុស្សប្រុសប៉ុណ្ណោះដែលអាចធ្វើឲ្យមនុស្សស្រីមានផ្ទៃពោះបាន

យេនឌ័រ/ស្រ្តីនិងបុរសអាចធ្វើការងារជាគ្រូបង្រៀនវិស្វករកម្មករ/ស្រ្តីនិងបុរសអាចមើលថែកុមារនិងមនុស្សចាស់ ហើយទាំងប្រុសទាំងស្រី ក៏អាចធ្វើការងារផ្ទះបានដែរ។

# ការរំពឹងទុករបស់សង្គមអំពីស្ត្រីនិងបុរស

- **ទំនោរផ្ទាល់ខ្លួន៖** មនុស្សស្រីមានលក្ខណៈអកម្មនិងស្ថិតនៅក្រោមគេ / បុរស មានទំនុកចិត្តលើខ្លួនឯងនិងច្រឡេងច្រឡាង។
- **អាកប្បកិរិយានៅក្នុងផ្ទះ៖** ការថែទាំគឺសម្រាប់ស្ត្រី / ការជួសជុលផ្ទះគឺសម្រាប់បុរស។
- **មុខរបរ៖** គិលានុបដ្ឋាកនិងលេខាច្រើនតែជាមុខរបររបស់ស្ត្រី / វិស្វករនិងកម្មករសំណង់ ច្រើនតែជារបស់បុរស។
- **រូបរាងខាងក្រៅ៖** គេច្រើនរំពឹងថាមនុស្សស្រីមាឌតូចនិងទន់ភ្លន់/ បុរសច្រើនតែខ្ពស់ និងមានស្មាទូលាយ។




# ប៉ុន្តែ...

ភាពខុសគ្នាផ្នែកជីវសាស្ត្រមិនអាចពន្យល់បានថាតើហេតុអ្វីបានជាស្ត្រីនិងបុរសដើរតួនាទីខុសគ្នានៅក្នុងសង្គម។ ភាពខុសគ្នាទាំងអស់នេះមិនអាចពន្យល់បានថាតើហេតុអ្វីបានជា ជាទូទៅមានការផ្តល់តម្លៃខុសគ្នាចំពោះតួនាទីស្ត្រីនិងតួនាទីរបស់បុរស។

# ចំណុចគួរឲ្យគិត...




?

# ចេញពីបរិដ្ឋានយេនឌ័រនេះ...

តើអ្វីខ្លះដែលស្ត្រី និងបុរស អាច/ត្រូវ **ធ្វើ រីករាយ ស្លៀកពាក់ ទៅ** ឬ **សម្តែងអាកប្បកិរិយា** នៅក្នុងសង្គមរបស់យើង?

# តួនាទីផ្នែកយេនឌ័រ

- របៀបដែលមនុស្សមានសកម្មភាពធ្វើនិងនិយាយដើម្បីបង្ហាញចេញមកនូវលក្ខណៈដែលខ្លួនជាកុមារី ឬកុមារា មនុស្សស្រី ឬមនុស្សប្រុស។

- មានលក្ខណៈខុសគ្នាយ៉ាងខ្លាំងពីវប្បធម៌មួយទៅវប្បធម៌មួយ ពីក្រុមជាតិពន្ធុមួយ ទៅក្រុមជាតិពន្ធុមួយទៀត និងពី វណ្ណៈសង្គមមួយ ទៅវណ្ណៈសង្គមមួយទៀត។

- វប្បធម៌និមួយៗ មានកំណត់តួនាទីផ្នែកយេនឌ័រ ពោលគឺវប្បធម៌ទាំងអស់សុទ្ធតែមានការរំពឹងទុក អំពីរបៀបដែលមនុស្សស្រី និងមនុស្សប្រុស កុមារី និងកុមារា គួរស្លៀកពាក់ មានអាកប្បកិរិយា និងសម្លឹងមើល។

# យេនឌ័រនៅក្នុងសង្គម៖ តើយើងរៀនអំពីតួនាទីយេនឌ័ររបស់យើងដោយរបៀបណា?

• យេនឌ័រដែលកំណត់រូបរាងដោយសង្គម៖ កុមាររៀនអំពីតួនាទីយេនឌ័រតាំងពីនៅតូចៗ ពី៖

- ✓ ឪពុកម្តាយនិងគ្រួសាររបស់ខ្លួន
- ✓ សាសនារបស់ខ្លួន
- ✓ វប្បធម៌របស់ខ្លួន
- ✓ ពិភពខាងក្រៅ
- ✓ ទូរទស្សន៍ ទស្សនាវដ្តីនិងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត។

# ហេតុនេះ... តួនាទីផ្នែកយេនឌ័រគឺជា

**អាកប្បកិរិយាដែលបានរៀនសូត្រ**នៅក្នុងសង្គម/សហគមន៍ជាក់លាក់ណាមួយដោយរួមមានសកម្មភាពការងារអាកប្បកិរិយា ការទទួលខុសត្រូវដែលត្រូវបានចាត់តាំងសម្រាប់បុរសនិងស្ត្រី។

ការចាត់តាំងនូវតួនាទីផ្នែកយេនឌ័ររងឥទ្ធិពលពីកត្តានានាដូចជា**អាយុវណ្ណៈជាតិពន្ធុជាតិសាសន៍ សាសនា**។

អាកប្បកិរិយាសង្គមដែលពាក់ព័ន្ធនឹងយេនឌ័រៗគឺជាគំរូអាកប្បកិរិយាដែលគេរំពឹងទុកដែលត្រូវបានរៀនសូត្រហើយដែលខុសៗគ្នាពីសង្គមមួយទៅសង្គមមួយ ឬពីវប្បធម៌មួយទៅវប្បធម៌មួយ។

តួនាទីយេនឌ័រមានការអភិវឌ្ឍជាបន្តបន្ទាប់ ហេតុនេះ តួនាទីយេនឌ័រគឺជាផលិតផលដែលកើតចេញនៅក្នុងម័យកាលជាក់លាក់...

... ហើយមានចំណងទាក់ទងជាចាំបាច់ជាមួយបំណែងចែកពលកម្មនៅក្នុងសហគមន៍ និងសង្គម។

យើងអាចបែងចែក**ការងារ**ទាំងអស់នេះទៅជាសកម្មភាពក្នុងវិស័យចំនួនបី៖ **ផលិតឡើងវិញផលិតនិងការងារសហគមន៍**

# តួនាទីការងារបីរបស់ស្ត្រី

**ការងារផលិត** គឺជាការងារបង្កើត**ចំណូលផ្នែកសេដ្ឋកិច្ច** សម្រាប់គ្រួសារ

**ការងារថែទាំ-ការងារផ្ទះ** ការងារថែទាំគ្រួសារ និងសហគមន៍ **ដោយគ្មានចំណូល**

**ការងារសហគមន៍** គាំទ្រ**កម្មវិធី និងសេវាសង្គម៖** ពិធីបុណ្យ ការកែលំអរសហគមន៍ សកម្មភាពនយោបាយ...

* * *

**ជារឿយៗ គេតែងតែអាចមើលឃើញវិសមភាពរវាងស្ត្រី និងបុរសយ៉ាងច្បាស់ នៅក្នុងបំណែងចែកពលកម្មក្នុងសង្គមនានា។**

វិទ្យាស្ថានបើកទូលាយ Open Institute

គេមើលមិនឃើញ/មានតម្លៃ
ផ្នែកសង្គមទាប ឬគ្មានតម្លៃ

គ្មានពេលវេលាដើម្បីទៅសាលារៀន
ឬដើម្បីបន្តការសិក្សា គ្មានជំនាញ
គ្មានមធ្យោបាយ គ្មានទំនុកចិត្ត
ចំពោះខ្លួនឯង.... ជាហេតុធ្វើឲ្យគ្មាន
ការទុកចិត្តពីសង្គមដែរ

## តួនាទីផ្នែកផលិតឡើងវិញ

ការទទួលខុសត្រូវច្រើន៖
ការរំពឹងទុកផ្នែកសង្គម
ក្លាយជាញាណមួយនៅក្នុង
ខ្លួនតែម្តង

↓

ពេលវេលា
ការគិត
ក្តីបារម្ភ
ថាមពលផ្នែកស្មារតី

## តួនាទីផ្នែកផលិត

ឋានៈទាប
ប្រាក់ឈ្នួលទាប
លទ្ធភាពតិចដើម្បី
អភិវឌ្ឍអាជីព
ការអភិវឌ្ឍខ្លួនឯង
ទាប

## តួនាទីសហគមន៍

ការចូលរួមតិច
ចូលរួមវិភាគទាន
តិចក្នុងការអភិវឌ្ឍ
សហគមន៍ដែល
សង្គមផ្តល់តម្លៃ

គ្មានសម្លេង គ្មាន
ជម្រើស

ការបែងចែកការងារ

# “សុបិន្តមិនអាចក្លាយជាការពិត...” (IMPOSSIBLE DREAM)

http://www.youtube.com/watch?v=F_UGCDSXpww

# ផ្តត់គំនិតសង្គមអំពីយេនឌ័រ






# តើផ្នត់គំនិតសង្គមអំពីយេនឌ័រគឺជាអ្វី?

- ផ្នត់គំនិតសង្គម គឺជាការវិនិច្ឆ័យ ឬភាពលំអៀង ដែលត្រូវបានគេទទួលស្គាល់ និងចាត់ទុកថាជារឿងសាមញ្ញ ទាក់ទងនឹងមនុស្សម្នាក់ ឬមនុស្សមួយក្រុម។




- **ផ្នត់គំនិតសង្គម** បង្កឲ្យមានការប្រព្រឹត្តិដោយមិនស្មើរភាព និងមិនយុត្តិធម៌ អាស្រ័យដោយយេនឌ័ររបស់មនុស្សណាម្នាក់។

  – ទង្វើនេះ ហៅថាការប្រកាន់ភេទ។

# ការបង្កើតផ្នត់គំនិតសង្គមអំពីយេនឌ័រ

គឺជាការបង្ហាញជាប្រចាំអំពីស្ត្រី និងបុរស ថាកាន់កាប់តួនាទីនានា ដោយផ្អែកលើបញ្ញត្តិបែបប្រពៃណី អំពីភាពជាបុរស និងភាពជាស្ត្រី។ ជារឿយៗ **ផ្នត់គំនិតសង្គមជួយជម្រុញនូវវប្បធម៌នៃវិសមភាពយេនឌ័រ** និង**ធ្វើឲ្យសកម្មភាពរើសអើង** ប្រឆាំងបុគ្គលនានា ជាពិសេសគឺស្ត្រី **ក្លាយជារឿងស្របច្បាប់។**

# ឧទាហរណ៍មួយចំនួន...

កូនប្រុសម្នាក់ ស្មើរនឹងកូនម្នាក់ កូនស្រីពីរនាក់ស្មើរនឹងគ្មានកូន (**វៀតណាម**)

មនុស្សប្រុសប្រៀបដូចមាសទឹកដប់ មនុស្សស្រីប្រៀបដូចជាក្រណាត់ស (**កម្ពុជា**)

ស្ត្រីមានសក់ខ្លី តែមានគំនិតខ្លី (**ម៉ុងហ្គោល**)

# លក្ខណៈសម្បត្តិរបស់ស្ត្រី/បុរស

...និង

# ផ្តត់គំនិតចាស់គំរិលអំពីតួនាទីយេនឌ័រ

# តើអ្វីជាភាពជាស្ត្រី? តើអ្វីជាភាពជាបុរស?

និន្នាការ**របស់ស្ត្រី** គឺជាបែបបទនៃអាកប្បកិរិយា ដែលសង្គមរបស់យើង ច្រើនតែផ្សារភ្ជាប់ទៅនឹង ភាពជាកុមារី ឬស្ត្រី។

និន្នាការ**របស់បុរស** គឺជាវិធីនៃការសម្តែងអាកប្បកិរិយា ដែលវប្បធម៌របស់យើងច្រើនតែផ្សាភ្ជាប់ជាមួយនឹងភាពជាកុមារា ឬមនុស្សប្រុស។

# ពាក្យដែលគេច្រើនប្រើដើម្បីពិពណ៌នាអំពីភាពជាស្ត្រី

- អាស្រ័យលើគេ
- អណ្តែតអណ្តូង
- អកម្ម
- ឆាប់រំជួលចិត្ត
- ស្ងាត់ស្ងៀម
- ទន់ភ្លន់
- ស្លូតបូតមិនដឹងអី
- ខ្សោយ
- ចូលចិត្តលេងសើច
- ព្វកែថៃទាំ
- រិះគន់ខ្លួនឯង
- ទន់ជ្រាយ
- អសកម្មផ្នែកភេទ
- ទទួលយក



# ពាក្យដែលគេតែងប្រើដើម្បីពិពណ៌នាភាពជាបុរស

- ឯករាជ្យ
- មិនអណ្តែតអណ្តូង
- ច្រងេងច្រងាង
- ប្រកួតប្រជែង
- ជាអ្នកផ្គត់ផ្គង់គេ
- មានបទពិសោធន៍ច្រើន
- ខ្លាំង
- សកម្ម
- មានទំនុកចិត្តលើខ្លួនឯង
- រឹងប៉ឹង
- ជាអ្នកនាំមុខផ្នែកភេទ
- ចូលចិត្តប្រឆាំង



# សូមចងចាំ...

- ច្បាស់ណាស់ថា ការបែងចែករបស់សង្គមទៅជាភាពជាបុរស និងភាពជាស្ត្រី គឺមិនមានលក្ខណៈជាក់ស្តែងឡើយ។ បំណែងចែកទាំងនេះ មិនបានក្រសោបយកនូវអារម្មណ៍ពិត អាកប្បកិរិយាពិត ឬនិយមន័យពិតរបស់ខ្លួនយើងឡើយ។

- បុរសទាំងអស់សុទ្ធតែមាននិន្នាការដែលគេហៅថាជានិន្នាការរបស់ស្ត្រី ហើយស្ត្រីទាំងអស់សុទ្ធតែមាននិន្នាការដែលគេហៅថាជានិន្នាការរបស់បុរស។

- ជាងនេះទៅទៀត យើងអាចនឹងបង្ហាញនិន្នាការខុសគ្នា ក្នុងពេលផ្សេងគ្នា។ វប្បធម៌របស់យើងបង្រៀនមនុស្សស្រី និងមនុស្សប្រុសឲ្យមានលក្ខណៈផ្ទុយពីគ្នា លើចំណុចជាច្រើន។ ប៉ុន្តែតាមពិតពួកយើងមានចំណុចដូចគ្នា ច្រើនជាងចំណុចខុសគ្នា។

# មនុស្សជាតិធំធាត់ឡើងនៅក្នុងអាកប្បកិរិយាសង្គម ដែលត្រូវបានផ្ទេរ និងអនុវត្តតាមពីមួយជំនាន់ទៅមួយជំនាន់មួយ...



# ប៉ុន្តែ តើនឹងមានអ្វីកើតឡើងប្រសិនបើ...



# តើបំណែងចែករវាងស្ត្រី និងបុរសទាំងនេះ មានប្រភពមកពីណា?

មនុស្សម្នាក់មិនមែន
កើតមកជាស្រីទេ
ប៉ុន្តែគេក្លាយជាស្រី

ស៊ីម៉ូន ដឺ ប៊ូវ័រ



# ការចូលរួមក្នុងសង្គម និងការរៀនសូត្រអំពីយេនឌ័រ

អ្វីដែលយើងមានក្នុងនាមជាបុរស និងជាស្ត្រី តួនាទីដែលយើងអភិវឌ្ឍ ទីតាំងដែលយើងកាន់កាប់ **គឺមិនមែនជាអ្វីដែលបានមកពីធម្មជាតិនោះទេ ប៉ុន្តែនេះជាអ្វីដែលយើងបានរៀនមក។**

***

ទាំងអស់នេះ **ត្រូវបានកំណត់ដោយការងារ និងការទទួលខុសត្រូវដែលត្រូវបានកំណត់ទៅឲ្យយេនឌ័រនិមួយៗ** (ប្រុស និងស្រី)



# តួនាទីផ្នែកយេនឌ័រ និងផ្នត់គំនិតសង្គម មិនមែនជាអ្វីដែលមិនប្រែប្រួល មិនមែនជាអ្វីដែលស្ថិតនៅជារៀងរហូតនោះទេ...

តួនាទីផ្នែកយេនឌ័រ និងផ្នត់គំនិតសង្គម តែងមានការផ្លាស់ប្តូរពីពេលមួយទៅពេលមួយ ហើយតែងអាស្រ័យលើវណ្ណៈ ជាតិពន្ធុ វប្បធម៌...

* * *

តួនាទីផ្នែកយេនឌ័រ និងផ្នត់គំនិតសង្គម ត្រូវបានបង្កើតឡើងដោយសង្គម និងជាអ្វីដែលយើងរៀនសូត្រតៗគ្នាមក។

ភាពខុសគ្នា មិនបង្កឲ្យមានវិសមភាពដោយខ្លួនឯងនោះទេ ប៉ុន្តែ ចាប់ពីពេលដែលក្រុមសង្គមចាប់ផ្តើមកំណត់តម្លៃ ឬកំណត់ឋានៈ ឲ្យភាពខុសគ្នាទាំងអស់នេះ ធ្វើឲ្យស្ថានភាពផ្លាស់ប្តូរ ហើយវិសមភាពក៏កើតមានឡើង និងជះឥទ្ធិពលទៅលើការអភិវឌ្ឍ និងសុខមាលភាពរបស់ស្ត្រី និងបុរស។

- វិសមភាពលើតម្លៃផ្នែកសង្គម រារាំងមនុស្សក្នុងយេនឌ័រទាំងពីមិនឲ្យមានលទ្ធភាពស្មើរគ្នាក្នុងការទទួលបានឱកាសនានាជាច្រើន

- មិនមានមនុស្សណាម្នាក់ស្នើសុំឲ្យមានភាពខ្ពស់ជាង ឬភាពទាបជាងដោយខ្លួនឯងឡើយ → យេនឌ័រកំណត់ឲ្យយើងស្ថិតនៅក្នុងទីតាំងណាមួយក្នុងចំណោមទីតាំងទាំងពីរនេះ។

# ហេតុនេះ តើហេតុអ្វីបានជាយើងចាំបាច់ត្រូវគិតអំពីការផ្លាស់ប្តូរផ្នែកយេនឌ័រ?

ភាពខុសគ្នាផ្នែកភេទ

≠

វិសមភាពផ្នែកសង្គម

ស្វែងរកលទ្ធផលកើតចេញពីការបង្កើតឡើងរបស់សង្គមនេះ

# តើស្ថានភាពអ្វីខ្លះដែលយើងអាចមើលឃើញភាពខុសគ្នាផ្នែកយេនឌ័រ

- **សង្គម៖** ការយល់ឃើញ និងការរំពឹងទុកផ្សេងគ្នា សម្រាប់ស្ត្រី និងបុរស

- **នយោបាយ៖** ភាពខុសគ្នានៅក្នុងវិធីដែលស្ត្រី និងបុរសកាន់កាប់ និងចែករំលែកអំណាច និងការចូលរួមក្នុងដំណើរការនៃការសម្រេចចិត្ត។

- **សេដ្ឋកិច្ច៖** ភាពខុសគ្នាផ្នែកលទ្ធភាពរបស់បុរស និងស្ត្រីក្នុងការទទួលបានអាជីពដែលមានតម្លៃច្រើន និងការគ្រប់គ្រងលើធនធានហិរញ្ញវត្ថុ។

- **ការអប់រំ៖** ភាពខុសគ្នាផ្នែកឱកាសទទួលបានការអប់រំ និងការរំពឹងទុករបស់ស្ត្រី និងបុរស។

# បំណែងចែកការងារផ្អែកយេនឌ័រ

តួនាទី ការទទួលខុសត្រូវ និងសកម្មភាពនានា ដែលត្រូវបានកំណត់ទៅឲ្យស្ត្រី និងបុរសដោយផ្អែកលើយេនឌ័រ



# វិស័យខុសគ្នា វត្តមានមិនស្មើភាពគ្នា

## បុរស

ផលិត-រកចំណូល និងវិស័យសាធារណៈ

ថៃទាំ និងផ្ទះសម្បែង

## ស្ត្រី

# ឧបសគ្គដែលមើលមិនឃើញ

ឥរិយាបទ នីតិវិធី និងកាលៈទេសៈ (ដែលជាលទ្ធផលនៃការរំពឹងទុក វិធាន និងតម្លៃបែបប្រពៃណី ដែលដាក់កំហិតលើការអភិវឌ្ឍរបស់ស្ត្រី នៅក្នុងដំណើរការដូចជាការសម្រេចចិត្ត និងស្វ័យភាព និងរារាំងមិនឲ្យស្ត្រីអាចចូលរួមយ៉ាងពេញលេញនៅក្នុងសង្គម

ការរំពឹងទុក តម្លៃ សង្គម។

# ល័ក្ខខ័ណ្ឌ/ទីតាំង

**ល័ក្ខខ័ណ្ឌ**/ស្ថានភាពចំពោះមុខ ផ្នែកសម្ភារៈ

**ទីតាំង**/ទីកន្លែងរបស់បុរស និងស្ត្រី នៅក្នុងសង្គម៖ អំណាច ឋានៈ និងការគ្រប់គ្រងលើការសម្រេចចិត្ត និងធនធាន។

- **ការគ្រប់គ្រង**/ សំដៅទៅលើវិស័យ ទ្រព្យសម្បត្តិ និង អំណាចការសម្រេចចិត្ត។

**អត្ថប្រយោជន៍/** ផ្នែកសេដ្ឋកិច្ច សង្គម នយោបាយ និងចិត្តសាស្ត្រ ដែលកើតចេញពីការប្រើប្រាស់ធនធាន។

**ឱកាស/** ឱកាសក្នុងការមានសមត្ថភាពទាំងផ្លូវកាយ និងផ្លូវចិត្ត ដើម្បីឈានទៅរកគោលដៅនៅក្នុងជីវិត។

# វិបាកសំខាន់ៗ

- ភាពក្រីក្ររបស់ស្ត្រីកាន់តែកើនឡើង
- ការបំពានជាប្រព័ន្ធទៅលើសិទ្ធិមនុស្សរបស់ស្ត្រី និងកុមារី
- ការរើសអើងផ្នែកយេនឌ័រ
- អំពើហិង្សាផ្នែកយេនឌ័រ
- អ្នកដទៃមើលមិនឃើញ

វិទ្យាស្ថានបើកទូលាយ Open Institute

# ការរើសអើង ផ្អែកយេនឌ័រ

# ការរើសអើងផ្នែកយេនឌ័រ គឺជាការប្រព្រឹត្តិជាប្រព័ន្ធ មិនអំណោយផលចំពោះបុគ្គលណាមួយ ដោយឈរលើមូលដ្ឋាននៃយេនឌ័ររបស់បុគ្គលនោះ ដែលជាការបដិសេធនូវសិទ្ធិ ឱកាស ឬធនធានរបស់ពួកគេ។ នៅទូទាំងពិភពលោក ស្ត្រីបានទទួលការប្រព្រឹត្តិដោយមិនស្មើរភាពចំពោះខ្លួន ហើយមានការផ្តល់តម្លៃទាបចំពោះជីវិតរបស់ពួកគេ អាស្រ័យដោយយេនឌ័ររបស់ពួកគេ។

ភាពមិនដូចគ្នានៃលទ្ធភាពរបស់ស្ត្រី ក្នុងការទទួលបានអំណាច និងគ្រប់គ្រងលើធនធាន គឺជាចំណុចស្នូលនៃការរើសអើងនេះ នៅក្នុងវិស័យស្ថាប័នទាំងអស់ រួមមានគ្រួសារ សហគមន៍ ទីផ្សារ និងរដ្ឋ។

# ឧទាហរណ៍មួយចំនួន...

- កង្វះអាហាររូបត្ថម្ភរបស់ស្ត្រី៖ ទឹកជំនន់នៅប្រទេសបង់ក្លាដេស។
- ការរំលូតកូនដោយជ្រើសរើសភេទ៖ ប្រទេសចិន និងវៀតណាម
- ប្រាក់ឈ្នួលមិនស្មើគ្នា សម្រាប់ការងារដូចគ្នា និងគុណវុឌ្ឍស្មើគ្នា៖ ប្រទេសអេស្ប៉ាញ

## ធ្វើឲ្យគេមើលឃើញអំពីល័ក្ខខ័ណ្ឌ និងស្ថានភាពដ៏អាក្រក់របស់ស្ត្រី នៅក្នុងវិស័យសង្គមទាំងអស់ ដូចខាងក្រោម...

- តថភាពនៃការរើសអើងចំពោះលទ្ធភាពក្នុងការទទួលបានសេវាជាមូលដ្ឋាន៖ អាហារ សុខភាព ការអប់រំ
- ការងារផលិតឡើងវិញរបស់ស្ត្រី
- ការងារផលិតរបស់ស្ត្រី
- តួនាទីជាថ្នាក់ដឹកនាំ
- ភាពជាពលរដ្ឋ
- ការមើលឃើញពីអ្នកដទៃ និងការទទួលស្គាល់ផ្នែកសង្គម

វិទ្យាស្ថានបើកទូលាយ Open Institute

- សារៈសំខាន់នៃការចូលរួមផ្នែកនយោបាយ នៅក្នុងសង្គមដែលមានការទទួលស្គាល់។
- ការទាមទារផ្នែកយេនឌ័រ។
- អន្តរទំនាក់ទំនងរវាងវត្ថុបំណងនៃសមភាព។
- ការចូលរួមវិភាគទានរបស់ស្ត្រី នៅក្នុងការអភិវឌ្ឍ។
- សិទ្ធិផ្លូវភេទ និងសិទ្ធិផ្នែកការបន្តពូជ
- ផ្នត់គំនិត និងឥរិយាបទរបស់សង្គមចំពោះស្ត្រី៖ ផ្នត់គំនិតសង្គមផ្នែកយេនឌ័រ។

# អំពើហិង្សាផ្អែក
# យេនឌ័រ

# អំពើហិង្សាគឺជា...

ការប្រើប្រាស់កំលាំង ឬអំណាចផ្លូវកាយដោយចេតនា ជាការគម្រាម ឬជាទង្វើជាក់ស្តែង ប្រឆាំងនឹងខ្លួនឯង ឬមនុស្សផ្សេងទៀត ឬប្រឆាំងនឹងក្រុម ឬសហាគមន៍មួយ ដែលបង្ករជាលទ្ធផល ឬទំនងជានឹងធ្វើឲ្យមានរបួសស្នាម ស្លាប់ គ្រោះថ្នាក់ផ្លូវចិត្ត ការអភិវឌ្ឍមិនល្អ ឬការដកហូត។

(អង្គការសុខភាពពិភពលោក WHO)

# អំពើហិង្សាក្នុងគ្រួសារ

... បង្កើតនូវការបំភិតបំភ័យ ការធ្វើបាប ការវាយដំ ការធ្វើបាបផ្លូវភេទ ឬអាកប្បកិរិយារំលោភបំពានដទៃទៀត ដែលធ្វើឡើងដោយសមាជិកណាម្នាក់នៅក្នុងគ្រួសារ សមាជិកនៅក្នុងផ្ទះ ឬដៃគូរជិតស្និទ្ធ ទៅលើសមាជិកម្នាក់ទៀត។

# អំពើហិង្សាផ្អែកយេនឌ័រ

"អំពើហិង្សា ដែលពាក់ព័ន្ធនឹងមនុស្សប្រុស និងមនុស្សស្រី ដោយក្នុងនោះ **មនុស្សស្រី ច្រើនតែជាជនរងគ្រោះ** ហើយដែលមានប្រភពកើតចេញពីទំនាក់ទំនង **អំណាចមិនស្មើគ្នា**រវាងបុរស និងស្ត្រី។ អំពើហិង្សា ត្រូវបានធ្វើឡើងប្រឆាំងនឹងស្ត្រីដោយផ្ទាល់ ដោយសារតែពួកគេគឺជាស្ត្រី ឬដែលជះឥទ្ធិពលលើស្ត្រីក្នុងទំហំធំផេងជាង។

អំពើហិង្សាផ្អែកយេនឌ័រ រួមមានការបង្ករគ្រោះថ្នាក់ផ្អែករាងកាយ ផ្លូវភេទ និងផ្លូវចិត្ត (រួមទាំងការបំភិតបំភ័យ ការរងទុក្ខ ការបង្ខិតបង្ខំ និង/ឬការដកហូតសេរីភាពនៅក្នុងសហគមន៍ទូទៅ)។ អំពើហិង្សាផ្អែកយេនឌ័រ ក៏រួមទាំងអំពើហិង្សាដែលរដ្ឋជួយធ្វើឲ្យសាយភាយ ឬប្រព្រឹត្តិដោយរដ្ឋផងដែរ។"

(និយមន័យដកស្រង់ពីក្រុមប្រធានបទយេនឌ័ររបស់អង្គការ UNFPA ឆ្នាំ1998)

រាល់ទង្វើ**អំពើហិង្សាផ្នែកយេនឌ័រ** ទាំងឡាយណា ដែលបង្ករលទ្ធផល ឬទំនងជានឹងបង្ករលទ្ធផលឲ្យមានគ្រោះថ្នាក់ផ្នែកផ្លូវការ ផ្លូវភេទ ឬផ្លូវចិត្ត ចំពោះស្ត្រី រួមទាំងការគម្រាមធ្វើទង្វើប្រភេទនេះ ការបង្ខិតបង្ខំ ឬការដកហូតសេរីភាពតាមអំពើចិត្ត មិនថាកើតឡើងនៅក្នុងទីសាធារណៈ ឬក្នុងជីវិតឯកជនឡើយ។

ហេតុនេះ អំពើហិង្សាចំពោះស្ត្រី រួមបញ្ចូលនូវសកម្មភាពដូចខាងក្រោម៖

ក) អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតមានឡើងនៅក្នុង**គ្រួសារ** រួមទាំងការវាយដំ ការរំលោភបំពានផ្លូវភេទទៅលើកុមារីនៅក្នុងគ្រួសារ អំពើហិង្សាទាក់ទងនឹងបណ្ណាការ ការរំលោភសេពសន្ថវៈក្នុងចំណងអាពាហ៍ពិពាហ៍ ការចៀរប្រដាប់ភេទស្ត្រី និងការអនុវត្តបែបប្រពៃណីដទៃទៀត ដែលបង្ករគ្រោះថ្នាក់ដល់ស្ត្រី អំពើហិង្សាពីសំណាក់មនុស្សមិនមែនជាស្វាមី និងអំពីហិង្សាទាក់ទងនឹងការកេងប្រវ័ញ្ចន៍។

ខ) អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែលកើតមានឡើងនៅក្នុង**សហគមន៍**ទូទៅ រួមទាំងការរំលោភសេពសន្ថវៈ ការរំលោភបំពានផ្លូវភេទ ការបៀតបៀនផ្លូវភេទ និងការបំភិតបំភ័យនៅកន្លែងធ្វើការ ក្នុងស្ថាប័នសិក្សា និងនៅកន្លែងដទៃទៀត ការជួញដូរស្ត្រី អំពើពេស្យាចារ្យដោយបង្ខំជាដើម។

គ) អំពើហិង្សាផ្លូវកាយ ផ្លូវភេទ និងផ្លូវចិត្ត ដែល**រដ្ឋ**ធ្វើឲ្យសាយភាយ ឬប្រព្រឹត្តិដោយរដ្ឋ មិនថារឿងនោះកើតឡើងនៅទីណាក្តី។

(និយមន័យដកស្រង់ចេញពី **សេចក្តីប្រកាសអង្គការសហប្រជាជាតិស្តីពីការលុបបំបាត់អំពើហិង្សាចំពោះស្ត្រី**)

# ប្រភេទនៃអំពើហិង្សាផ្នែកយេនឌ័រ

- **អំពើហិង្សាផ្លូវកាយ៖** ការវាយដំ ការទះតប់ ធាក់ ឬច្រាន

- **អំពើហិង្សាផ្លូវចិត្ត៖** ការបន្តុះបង្អាប់ ការប្រមាថ ការជេរ ការផ្តាច់ខ្លួនឲ្យនៅឯកោ

- **អំពើហិង្សាផ្លូវសេដ្ឋកិច្ច៖** ការគ្រប់គ្រងលុយកាក់ និងការដកហូតធនធានដែលចាំបាច់សម្រាប់សុខមាលភាពផ្នែកផ្លូវកាយ និងផ្លូវចិត្ត (រួមទាំងការថែទាំសុខភាព អាហាររូបត្ថម្ភ ការអប់រំ មធ្យោបាយចិញ្ចឹមជីវិត)

- **អំពើហិង្សាផ្លូវភេទ៖** ការរំលោភសេពសន្ថវៈ ការធ្វើបាប ការធ្វើទុក្ខទោស ឬការប៉ះពាល់ដោយគ្មានការយល់ព្រមពីបុគ្គលដែលពាក់ព័ន្ធ។

# អំពើហិង្សាផ្អែកយេនឌ័រក្នុងបរិបទកម្ពុជា

## DE IURE និងស្ថានភាពជាក់ស្តែង

CEDAW

ក្របខ័ណ្ឌការងារផ្នែកច្បាប់ និងផ្នែកគោលនយោបាយ

*ច្បាប់ស្ត្រី/ច្បាប់ប្រុស*

# ដំណកស្រង់ចេញពី “ច្បាប់ស្រី”

*ភ្លើងមួយគម្លែងក្រឡា   គឺប្ដីអាត្មា   បិតថេររួមរ័ក្ស។*
*ឲ្យនាងប្រណិប័តន៍ជៀងជាក់*   ***កុំធ្វើឲ្យអាក់   ឲ្យអន់ចិត្តប្ដី។***
*អត់ឱនខ្លាចខ្លួនជាស្រី*   ***កុំឲ្យស្រដី   ទុកគេជាស្មើ។***
*ទោះកើតហេតុភេទសារពើ   ពាក្យពុំប្រសើរ   ជញ្ជឹងចាំស្ដាប់។*

ទោះប្ដីស្រដីពុំគាប់ ពុំគួរឲ្យប្រាប់ បានដឹងដល់ម្ដាយ។
កើតខឹងវែងរឹងខ្វូរខ្វាយ លឺពាក្យពីម្ដាយ ខ្សឹបខ្សៀវប្រាប់ប្ដី។
មិនក្សាន្តបែកបានពីរបី កើតជាសម្ដី សួរចុះសួរឡើង។
ពុំស្ងាត់ស្ងៀមមាត់ចចើង ជជែកនាំឡើង ចចើងមិនបាត់។
តតាំងពាក្យខ្លាំងមិនស្ងាត់ មិនស្ងៀមឲ្យបាត់ ឲ្យបានទីសុខ។
ជជែកស្ទើរបែកទាំងស្រុក មិនមានហៅសុខ យូរលង់ឡើយនៃ។

# កត្តា ឬបុព្វហេតុដែលបង្ករឲ្យមានអំពើហិង្សាផ្នែកយេនឌ័រ

-លក្ខខណ្ឌផ្នែកយេនឌ័រ

-បរិបទគ្រួសារ

-ភាពស្មុគ្រស្មាញនៃទំនាក់ទំនងសេចក្តីស្រលាញ់ ផ្លូវភេទ និងក្តីស្នេហា

-ឥរិយាបទសហាគមន៍

-ការលំបាកក្នុងការរកដំណោះស្រាយវិវាទដោយអហិង្សា

-កត្តាបុគ្គល៖ បទពិសោធន៍កន្លងមកជាមួយអំពើហិង្សា/ការប្រើប្រាស់គ្រឿងស្រវឹង និងថ្នាំញៀន/ការបាត់បង់អត្តសញ្ញាណ

# អ័ក្សនៃអន្តរាគមន៍ចំពោះអំពើហិង្សាផ្នែកយេនឌ័រ

-ដើម្បីពង្រឹងស្វ័យភាពរបស់ស្រ្តី

-ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ ជាយុទ្ធសាស្រ្តទោល

-ការសម្រុះសម្រួលក្នុងគ្រួសារ

-ផ្ទះជ្រកកោនបណ្ដោះអាសន្ន

-ការស្តារជនល្មើស

-ការគាំទ្រចំពោះស្រ្តីដែលបានរងនូវការរំលោភបំពាន

-ពលរដ្ឋមានការយកចិត្តទុកដាក់ចំពោះយេនឌ័រ

# បញ្ហាប្រឈម

ឥរិយាបទដែលមានជាប់មក៖ កម្លាំងវប្បធម៌ និងផ្នត់គំនិតសង្គម

→ ប្រពៃណី។

# បញ្ហាប្រឈម

អាជ្ញាធរ

អាជ្ញាធរនានា ដូចជា**មេភូមិ មេឃុំ** និង **ប៉ូលីសក្នុងមូលដ្ឋាន** នៅតែបន្តមានគំនិតថា អំពើហិង្សាក្នុងគ្រួសារ គឺជាបទល្មើសស្រាល ដែលនាំឲ្យពួកគេមានការអនុវត្តច្បាប់មិនបានត្រឹមត្រូវ និងធ្វើឲ្យស្ថានភាពកាន់តែអាក្រក់ឡើង។

↓

មូលដ្ឋានប្រាក់ឈ្នួល

# បញ្ហាប្រឈម

## ការធ្វើឲ្យស្ត្រីក្លាយជាជនរងគ្រោះ

- ស្ត្រីភាគច្រើនត្រូវពឹងពាក់លើការឧបត្ថម្ភរបស់ប្តីខ្លួនទាំងស្រុង
- ស្ត្រីក៏ប្រហែលជាខ្វះទំនុកចិត្តលើអាជ្ញាធរក្នុងការផ្តល់អន្តរាគមន៍ប្រកបដោយប្រសិទ្ធភាព

# បញ្ហាប្រឈមរបស់កម្ពុជា

- ខ្វះខាតធនធានប្រកបដោយប្រសិទ្ធភាព

-ខ្វះអ្នកមានវិជ្ជាជីវៈជំនាញ

-ជម្រកសុវត្ថិភាព

-យុទ្ធសាស្ត្រដើម្បីផ្សព្វផ្សាយ និងអនុវត្តខ្លឹមសាររបស់អនុសញ្ញា CEDAW និងសិទ្ធិស្ត្រី

-ការសម្របសម្រួលថ្នាក់ក្រសួង

# តើយុត្តិធម៌ ឬទេ?

## ក្របខ័ណ្ឌការងាររបស់យើង

- យុត្តិធម៌សង្គម
- សិទ្ធិមនុស្ស
- CEDAW



សមភាពរវាងស្ត្រី និងបុរស គឺជាបញ្ហាសិទ្ធិមនុស្ស និងជាល័ក្ខខ័ណ្ឌមួយសម្រាប់យុត្តិធម៌សង្គម ហើយក៏ជាកត្តាតម្រូវដ៏ចាំបាច់ និងជាមូលដ្ឋានសម្រាប់សមភាព ការអភិវឌ្ឍ និងសន្តិភាពផងដែរ។ ភាពជាដៃគូរដែលត្រូវបានកែប្រែដោយឈរលើសមភាពរវាងស្ត្រី និងបុរស គឺជាល័ក្ខខ័ណ្ឌមួយសម្រាប់ការអភិវឌ្ឍប្រកបដោយនិរន្តរភាព ដែលយកមនុស្សជាចំណុចកណ្តាល។

សន្និសីទពិភពលោកលើកទីបួន ស្តីពីស្ត្រី ឆ្នាំ ១៩៩៥



ដោយហេតុថា សមភាពយេនឌ័រគឺជាសំនួរមួយស្តីអំពី សិទ្ធិមនុស្ស និង យុត្តិធម៌សង្គម ហើយដោយឈរលើការសម្រុះសម្រួលធ្វើឡើងដោយភាគីរដ្ឋនិងការទទួលខុសត្រូវដែលចាំបាច់ដើម្បីសាងនូវសង្គមមួយដែលកាន់តែមានសមភាពខ្ពស់...

ប្រពៃណី ឬ ទំនៀមទំលាប់ និង
ច្បាប់សីលធម៌អាកប្បកិរិយា ដែល
ផ្អែកលើសាសនា និងច្បាប់ដទៃ
ទៀត មិនអាចក្លាយជាលេស ឬជា
ហេតុផលប្រឆាំងនឹងការប្រយុទ្ធ
ប្រឆាំងការរើសអើងផ្អែកយេនឌ័រ
និងអំពើហិង្សាផ្អែកយេនឌ័រទេ។

# បរិបទនៃភាពសមស្របផ្នែកអន្តរទំនាក់ទំនង

វប្បធម៌

សាសនា

ការបង្កបង្កើតឡើងនូវភាពពហុវប្បធម៌របស់រដ្ឋ

ផ្នត់គំនិត និងឥរិយាបទសហគមន៍

គ្រួសារ



# វប្បធម៌គឺជា...

ការវេញត្របាញ់ចូលគ្នានៃលក្ខណៈផ្នែកស្មារតី សម្ភារៈ បញ្ញា និង មនោសញ្ចេតនា ដែលជាលក្ខណៈសម្បត្តិរបស់សង្គម ឬក្រុមសង្គមមួយ។ វប្បធម៌ មិនមែនមានត្រឹមតែសិល្បៈ និងអក្សរតែប៉ុណ្ណោះទេ ប៉ុន្តែក៏រួមមាន បែបបទជីវិត សិទ្ធិមនុស្សជាមូលដ្ឋាន ប្រព័ន្ធតម្លៃ ប្រពៃណី និងជំនឿផងដែរ។

*សន្និសីទពិភពលោកស្តីអំពីគោលនយោបាយវប្បធម៌*

*ឆ្នាំ ១៩៨២*

# វប្បធម៌



- គឺជាផលិតផលដែលមនុស្សបង្កើតឡើង និងរបៀបធ្វើអន្តរកម្ម ទីកន្លែង នយោបាយ នឹងប្រវត្តិសាស្ត្រ។
- ឆ្លើយតបទៅនឹងតថភាពដែលផ្លាស់ប្តូររបស់មនុស្ស។

# វប្បធម៌ និងប្រពៃណីអាច៖

- ជួយជម្រុញ និង/ឬ បង្ករឧបសគ្គ
- គៀបសង្កត់ និង/ឬ រំដោះ
- ផ្តល់អំណាច និង/ឬ ដកហូតអំណាច

# តើយេនឌ័រ និងការផ្លាស់ប្តូរ មាន ទំនាក់ទំនងគ្នាដូចម្តេច?



# ចំណុចប្រសព្វគ្នារវាងវប្បធម៌ និងយេនឌ័រ

- វប្បធម៌មានចលនាជានិច្ច។ វប្បធម៌អាចរស់រានបាន តាមរយៈការឆ្លើយតបទៅនឹងតថភាពដែលមានការប្រែប្រួល។

- តួនាទីផ្នែកយេនឌ័រ ក៏មានចលនាជាប់ជានិច្ចដែរ។ តួនាទីផ្នែកយេនឌ័រអាចផ្លាស់ប្តូរ ហើយក៏កំពុងមានការផ្លាស់ប្តូរផងដែរ។

- តួនាទីយេនឌ័រដែលមានការវិវត្ត គឺជាផ្នែកមួយដ៏សំខាន់សម្រាប់ការវិវត្តដែលវប្បធម៌និមួយៗត្រូវធ្វើឡើង ដើម្បីអាចបន្តរស់រានបាន។

# បំលាស់ប្ដូរផ្នែកយេនឌ័រៈ តើហេតុអ្វីបានជាមានការប្រឆាំង?

- តួនាទីផ្នែកយេនឌ័រ កំណត់របរាងជីវិតប្រចាំថ្ងៃ។ ហេតុនេះ បំលាស់ប្ដូរផ្នែកយេនឌ័រ អាចជះឥទ្ធិពលលើមនុស្សជាច្រើន។
- បំលាស់ប្ដូរផ្នែកយេនឌ័រ ត្របាញ់ចូលគ្នា និងមានផលប៉ះពាល់លើចលនាផ្នែកអំណាចនៅក្នុងវណ្ណៈ ជាតិសាសន៍ សាសនា។ល។
- ទីតាំងនៃភាពសុខស្រួល ដែលបង្កើតឡើងដោយអត្តសញ្ញាណរបស់បុគ្គល និងក្រុម អាចរងនូវការគម្រាមកំហែង។
- វប្បធម៌ មានរចនាសម្ព័ន្ធអំណាច ដែលមានចំណូលចិត្តលើ "ភាពមិនប្រែប្រួល" ដែលផ្អែកលើភាពលំអៀងផ្នែកយេនឌ័រ។

# វឌ្ឍនភាពយេនឌ័រ→បើទោះជាមានការប្រឆាំងក្តី

- បុគ្គលមួយចំនួនមានទស្សនវិស័យ ចំណុចខ្លាំង និងភាពក្លាហាន ដើម្បីបញ្ឈប់ការគោរពតាម៖ **បំបែកតនាទីតាមផ្នត់គំនិតចាស់គំរិលអំពីយេនឌ័រ**

- ពួកគេប្រមែប្រមូលសម្ព័ន្ធភាព នៅក្នុងបរិដ្ឋានរបស់ខ្លួនផ្ទាល់។

- មនុស្សមួយចំនួនគឺជាចលករនៃចលនាសំខាន់ៗ៖ គន្ធី។

# យេនឌ័រជាទំនាស់
# យេនឌ័រជាឱកាស



# បំលាស់ប្តូរយេនឌ័រ អាចមានលក្ខណៈជាក់លាក់ទៅតាមទីកន្លែង

ការបកស្រាយឡើងវិញលើសម្លៀកបំពាក់ PURDHA អាចអនុញ្ញាតិឲ្យស្រ្តីបង់ក្លាដែសទៅធ្វើការនៅរោងចក្រកាត់ដេរបាន។

ប្រជាជនបញ្ឈប់ការរុំជើងនៅប្រទេសចិន។

ស្រ្តីទីមួយបានក្លាយជាអ្នកបើករថយន្តក្រុង នៅប្រទេស ប៉ាពួ ញ៉ូវហ្គីណេ។

# បំលាស់ប្តូរយេនឌ័រ អាចមានលក្ខណៈជាសាកល

បុរសកាន់តែច្រើនមានការទទួលខុសត្រូវលើការងារផ្ទះ និងការមើលថែកូន

មនុស្សស្រ្តីកាន់តែច្រើនមានតួនាទីសាធារណៈ និងតួនាទីដឹកនាំ



# បំលាស់ប្តូរផ្តល់ជម្រើស

ការផ្តួចផ្តើមមានការផ្លាស់ប្តូរផ្នែកវប្បធម៌ នាំឲ្យមានការផ្លាស់ប្តូរផ្នែកយេនឌ័រ។

សកម្មភាពដែលផ្អែកលើការវិភាគយេនឌ័រ អាចបង្កើតឲ្យមានការបើកចំហរដើម្បីជួយដល់អ្នកចាញ់ប្រៀប។

↓

សកម្មភាពនេះ អាចនាំឲ្យមានសមភាពយេនឌ័រកាន់តែច្រើននៅក្នុងនានាភាព។

# តើនរណា ឬអ្វី ដែលគួរជាមគ្គុទ្ទេសក៍របស់យើង?

ភ្នាក់ងារផ្លាស់ប្តូរក្នុងមូលដ្ឋាន → ក្តីក្លាហានរបស់មនុស្សក្នុងមូលដ្ឋាន។

ការបែងចែក៖ នៅក្នុងការវិភាគយេនឌ័រដែលផ្តោតលើបរិបទជាក់លាក់ → វប្បធម៌និមួយៗ មានបញ្ហាផ្នែកយេនឌ័រដោយឡែករបស់ខ្លួន។

# វប្បធម៌ និងយេនឌ័ររងឥទ្ធិពលពី...

សាកលភាវូបនីយកម្ម

បច្ចេកវិទ្យា ICT និងបច្ចេវិទ្យាដទៃទៀត

ការផ្លាស់ប្តូរនៅក្នុងទីផ្សារការងារ ឬក្នុងបរិដ្ឋានសេដ្ឋកិច្ច

ជំលោះប្រដាប់អាវុធ និងជំលោះនយោបាយ

គម្រោងអភិវឌ្ឍនានា

អតីតកាលជាអ្វីដែលយើង
ត្រូវគោរពបូជា ប៉ុន្តែ
អនាគតជាអ្វីដែលយើង
ត្រូវគោរពបូជាកាន់តែខ្លាំង
ថែមទៀត។



Ngoni Makivaza, ការអភិវឌ្ឍនៅអាហ្វ្រិច៖
ទស្សនវិស័យរបស់អាហ្វ្រិច និងបញ្ហា
ប្រឈមទៅកាន់មជ្ឈមណ្ឌល ឆ្នាំ ១៩៩៨។

# ស្វែងរកដំណោះស្រាយ



# ដំបូងត្រូវកំណត់អំពីអ្វីដែលយើងត្រូវការជាមុនសិន...

# សមភាពយេនឌ័រ



**សមភាពយេនឌ័រ៖** ស្ត្រី និងបុរសមាន**ល័ក្ខខ័ណ្ឌស្មើគ្នា** ក្នុងការទទួលបានសិទ្ធិមនុស្សពេញលេញរបស់ខ្លួន និងដើម្បីចូលរួមវិភាគទាន ព្រមទាំងទទួអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ច សង្គម វប្បធម៌ និងនយោបាយ។

**សមភាពយេនឌ័រ៖** សង្គមផ្តល់តម្លៃស្មើគ្នាចំពោះភាពដូចគ្នា និងភាពខុសគ្នារវាងបុរស និងស្ត្រី និងតួនាទីដែលបុរស និងស្ត្រីបំពេញ។

# តើបានមកពីណា?... សមធម៌

**ការប្រព្រឹត្តិដោយយុត្តិធម៌** ចំពោះស្ត្រី និងបុរស យោងទៅតាមសេចក្តីត្រូវការរបស់ពួកគេរៀងៗខ្លួន រួមទាំងការប្រព្រឹត្តិស្មើរគ្នា ឬការប្រព្រឹត្តិដែលត្រូវបានចាត់ទុកថាស្មើរគ្នា ក្នុងន័យនៃសិទ្ធិ អត្ថប្រយោជន៍ កាតព្វកិច្ច និងឱកាស។

ដើម្បីធានាបាននូវភាពយុត្តិធម៌ ចាំបាច់ត្រូវមាន**វិធានការនានា** ដើម្បី**ប៉ះប៉ូវសងវិញ** នូវភាពចាញ់ប្រៀបផ្នែកប្រវត្តិសាស្ត្រ និងសង្គម ដែលរារាំងមិនឲ្យស្ត្រី និងបុរសអាចប្រតិបត្តិការងារខ្លួនយ៉ាងពេញលេញ។

សកម្មភាពជាវិជ្ជមាន

# វត្ថុបំណងចំបងនៅក្នុងការលើកកំពស់សមភាពយេនឌ័រ ៖ ការបង្កើតល័ក្ខខ័ណ្ឌដែលមានសមធម៌

- ការផ្លាស់ប្តូរច្បាប់ តម្លៃផ្នែកវប្បធម៌ និងសាសនាដែលមានលក្ខណៈរើសអើង
- ការលុបបំបាត់នូវការអនុវត្តដែលមានលក្ខណៈរើសអើង
- ការផ្តល់អំណាចដល់ស្ត្រី៖ ស្វ័យភាពផ្នែកសេដ្ឋកិច្ច សង្គម និងនយោបាយ
- ការពង្រឹងសមត្ថភាព៖ ការចូលរួម និងភាពជាអ្នកដឹកនាំរបស់ស្ត្រី
- ការលើកកំពស់ការទទួលខុសត្រូវផ្នែកសង្គមរបស់ស្ត្រី និងបុរស និង រដ្ឋាភិបាល ដើម្បីលើកកំពស់សមភាពយេនឌ័រ

# ដោយរបៀបណា?



ព័ត៌មាន

↓

ការយល់ដឹង

↓

សកម្មភាព

# ព័ត៌មាន/ការបង្កើត



# អ្វីដែលយើងត្រូវដឹង…

សារតាផ្នែកយេនឌ័រ

↓

ស្ត្រីនិយម

↓

តើពាក្យយេនឌ័រមានប្រភពមកពីណា?

# ស្ត្រីនិយម

ចលនាទូទាំងពិភពលោកមួយ ដែលព្យាយាមលើកកំពស់ឋានៈផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គមរបស់ស្ត្រី និងតស៊ូដើម្បីទាមទារសមភាពយេនឌ័រនៅគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិត នៅក្នុងគ្រប់សង្គមទាំងអស់។

**វិវត្តជុំវិញនឹងនិកាយគំនិត និងចលនាសង្គម**

បញ្ញត្តិដែលនៅពីក្រោមគំនិតស្ត្រីនិយម បន្តវិវត្តទៅមុខ យោងទៅតាមបរិបទ ផ្នែកសេដ្ឋកិច្ចសង្គម នយោបាយ និងវប្បធម៌ ដែលចលនាកំពុងកើតឡើង។

# ក្របខ័ណ្ឌការងារអន្តរជាតិ

CEDAW

ប៉េកាំង

គោលដៅអភិវឌ្ឍសហសវត្ស

# ក្រលេកមើលទៅលើបរិបទសង្គមរបស់ខ្ញុំ... ប្រទេសកម្ពុជា...

- តើមានគម្លាតផ្នែកយេនឌ័រអ្វីខ្លះ?
- តើអ្វីជាបុព្វហេតុដែលនាំឲ្យមានគម្លាតទាំងអស់នេះ?
- តើអ្វីខ្លះជាសមាសធាតុសំខាន់ៗនៃវិសមភាពយេនឌ័រ នៅក្នុងប្រទេស/ខេត្ត/សហាគមន៍របស់ខ្ញុំ
- តើយើងត្រូវធ្វើអ្វីខ្លះ ដើម្បីលុបបំបាត់នូវវិបាកទាំងអស់នេះ?

# ការយល់ដឹង និងការទទួលខុសត្រូវ

- ការទទួលខុសត្រូវរបស់រដ្ឋាភិបាល
- ការទទួលខុសត្រូវរបស់សង្គមស៊ីវិល
- ការទទួលខុសត្រូវផ្ទាល់ខ្លួន/វិជ្ជាជីវៈ

# ការបញ្ជ្រាបយេនឌ័រ
# ការសម្រុះសម្រួលរបស់រដ្ឋាភិបាល ការទទួលស្គាល់របស់សង្គមស៊ីវិល

ការបញ្ជ្រាបយេនឌ័រ គឺជា**វិធីសាស្ត្រគន្លឹះ** ក្នុងការជម្រុញការអនុវត្ត កិច្ចខិតខំនានា ដើម្បីសម្រេចបាននូវសមភាពយេនឌ័រ។

នេះមានន័យថាមានការយកចិត្តទុកដាក់ទៅលើ **ទស្សនវិស័យ បទពិសោធន៍ និងសេចក្តីត្រូវការរបស់បុរស និងស្ត្រី** នៅក្នុងសកម្មភាពទាំងអស់ និងវិស័យទាំងអស់របស់សហគមន៍

**នៅគ្រប់បរិបទទាំងអស់៖** ការបញ្ជ្រាប អាចជះឥទ្ធិពលដល់សកម្មភាពរបស់អង្គការគ្រប់ប្រភេទទាំងអស់ ដូចជារដ្ឋបាលសាធារណៈ អង្គការក្រៅរដ្ឋាភិបាល គម្រោងសហប្រតិបត្តិការអភិវឌ្ឍៗលៗ

**សម្មាហរណកម្ម៖** ការលើកកំពស់សមភាពយេនឌ័រ លែងជាផ្នែកដាច់ដោយឡែករបស់ការសម្រេចចិត្តតទៅទៀតហើយ ប៉ុន្តែបានក្លាយជាផ្នែកដ៏សំខាន់មួយនៅក្នុងគ្រប់សកម្មភាពនៅគ្រប់កម្រិតទាំងអស់ៗ

ការបញ្ច្រាបគឺមិនមែនជាគោលដៅចុងក្រោយនោះទេ ប៉ុន្តែគឺជាមធ្យោបាយមួយដើម្បីសម្រេចគោលដៅចុងក្រោយ។

គោលដៅចុងក្រោយ ដែលត្រូវសម្រេចឲ្យបាន

នោះគឺសមភាពយេនឌ័រ។

# តើយើងធ្វើការងារសមភាពយេនឌ័រដោយវិធីណា?

1

**វិភាគតួនាទី ផ្នត់គំនិតសង្គម ទំនាក់ទំនង** និង **ដំណើរការ**ទាំងអស់ ដែលជាភស្តុតាងបង្ហាញនូវអតុល្យភាពយេនឌ័រ រវាងបុរស និងស្ត្រី និង **ការអនុវត្តប្រកបដោយការរើសអើងនានា** ដែលមានមូលដ្ឋានផ្អែកលើយេនឌ័រ។

2

**បែងចែកឡើងវិញ** ដោយយុត្តិធម៌ នូវការចូលរួមក្នុងសកម្មភាពនានា **លទ្ធភាពទទួលបាន និងគ្រប់គ្រង**លើធនធាន និងអត្ថប្រយោជន៍ ការផ្តល់តម្លៃដូចគ្នាទៅលើការងារផ្សេងៗគ្នា

**ការចោទសួរ** និងការព្យាយាមផ្លាស់ប្តូរការអនុវត្ត ពង្រឹង**ស្វ័យភាព និងជំនាញក្នុងការសម្រេចចិត្ត** សម្រាប់ស្ត្រី។

# 3

# ការវាយតម្លៃលើផលប៉ះពាល់ជាក់ស្តែង ឬ ផលប៉ះពាល់ដែលអាចមាន ស្តីពីល័ក្ខខ័ណ្ឌ និងទីតាំងរបស់បុរស និងស្ត្រី។

# ការវិភាគផ្នែកយេនឌ័រ

- **ការវិភាគផ្នែកយេនឌ័រ** គឺជាឧបករណ៍មួយដើម្បីកំណត់នូវ តួនាទី និងសេចក្តីត្រូវការរបស់ស្ត្រី និងបុរស នៅក្នុងបរិបទ និងបរិយាកាសគម្រោងជាក់លាក់ណាមួយ។

- **ការវិភាគផ្នែកយេនឌ័រ** អាចធ្វើឡើងនៅដំណាក់កាលណាក៏បាន ក្នុងអំឡុងវដ្តនៃគម្រោង ប៉ុន្តែប្រសិនបើដាក់នៅដំណាក់កាលធ្វើផែនការដំបូង និងដំណាក់កាលតាក់តែងគម្រោង។

# ការវិភាគផ្នែកយេនឌ័រ

- នៅក្នុងពិភពការងារ ការវិភាគផ្នែកយេនឌ័ររួមមានការពិនិត្យមើលទៅលើ៖
  - បំណែងចែកពលកម្មរវាងស្ត្រី និងបុរស
  - សេចក្តីត្រូវការផ្សេងគ្នា របស់ស្ត្រី និងបុរស នៅក្នុងពិភពការងារ
  - បំណែងចែកលទ្ធភាពទទួលបាន និងការគ្រប់គ្រងលើធនធាន និងអត្ថប្រយោជន៍ ដោយផ្អែកទៅលើភេទ
  - ឱកាស និងដែនកំណត់នៅក្នុងបរិដ្ឋានសង្គម និងសេដ្ឋកិច្ច
  - សមត្ថភាពរបស់យើងជាអង្គការ និងអង្គការដៃគូរដទៃទៀត ក្នុងការលើកកំពស់សមភាពរវាងស្ត្រី និងបុរស នៅក្នុងវិស័យមុខរបរ។

# តើត្រូវចាប់ផ្តើមដោយរបៀបណា?

## កំណត់ថាតើយើងនៅកន្លែងណា និងតើយើងមានអ្វីខ្លះ?

| | | |
|---|---|---|
| ឧបករណ៍ផ្នែកច្បាប់ (បទដ្ឋានអន្តរជាតិ) | → | ផ្តោតការយកចិត្តទុកដាក់លើគោលការណ៍ជាមូលដ្ឋាន |
| ឧបករណ៍ផ្នែកស្ថិតិ | → | ពិនិត្យរកមើលទិន្នន័យដែលបែងចែកទៅតាមយេនឌ័រ |
| ឧបករណ៍ផ្នែកវិធីសាស្រ្ត | → | យកវិធីសាស្ត្រផ្នែកយេនឌ័រទៅអនុវត្ត |

# ការប៉ាន់ប្រមាណតម្រូវការផ្នែកយេនឌ័រ

- **ការប៉ាន់ប្រមាណតម្រូវការផ្នែកយេនឌ័រ** ផ្សារភ្ជាប់យ៉ាងជិតស្និទ្ធជាមួយនឹងបញ្ញត្តិការវិភាគផ្នែកយេនឌ័រ៖ ទាំងពីរនេះ សុទ្ធតែជាឧបករណ៍វិភាគដ៏មានតម្លៃសម្រាប់ពង្រឹងសក្តានុពលរបស់គម្រោង ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងផលប្រយោជន៍ផ្សេងគ្នារបស់ស្ត្រី និងបុរស នៅក្នុងវដ្តនៃគម្រោងទាំងមូល។

- ការប៉ាន់ប្រមាណសេចក្តីត្រូវការផ្នែកយេនឌ័រ ជួយបង្ហាញឲ្យឃើញសេចក្តីត្រូវការផ្នែកយេនឌ័រ**ចំពោះមុខ និងជាយុទ្ធសាស្ត្រ។**

# សេចក្តីត្រូវការពាក់ព័ន្ធនឹងយេនឌ័រ

## សេចក្តីត្រូវការចំពោះមុខ/សេចក្តីត្រូវការជាយុទ្ធសាស្ត្រ

**សេចក្តីត្រូវការចំពោះមុខ៖** គឺជាសេចក្តីត្រូវការផ្នែកសម្ភារៈដែលចាំបាច់ត្រូវឆ្លើយតប ដើម្បីបំពេញ**តម្រូវការជាមូលដ្ឋាន** របស់ជីវិត។

**សេចក្តីត្រូវការចំពោះមុខ** គឺជាសេចក្តីត្រូវការ**ពាក់ព័ន្ធនឹងយេនឌ័រ** នៅពេលណាដែលការបំពេញតម្រូវការនោះ គឺជាការងាររបស់យេនឌ័រជាក់លាក់ណាមួយ។

**ការដោះស្រាយបញ្ហាទាក់ទងនឹងសេចក្តីត្រូវការផ្នែកយេនឌ័រចំពោះមុខ មិនផ្លាស់ប្តូរនូវទំនាក់អំណាចរវាងស្ត្រី និងបុរស នៅក្នុងសហគមន៍ឡើយ។**

សេចក្តីត្រូវការជាយុទ្ធសាស្រ្ត ទាក់ទងនឹងយេនឌ័រ គឺទាក់ទងជាមួយនឹងឋានៈរបស់ស្រ្តី និងបុរស និងរចនាសម្ព័ន្ធអំណាចនៅក្នុងសហគមន៍។

**យុទ្ធសាស្រ្ត**

បំបែកផ្នត់គំនិតសង្គម ចោទសួរទៅលើទំនាក់ទំនងយេនឌ័រៈ ផ្លាស់ប្តូរផ្នត់គំនិត

## សេចក្ដីត្រូវការចំពោះមុខ

ចំពោះមុខ និងរយៈពេលខ្លី។

មានលក្ខណៈពិសេសដោយឡែកសម្រាប់ស្ត្រីម្នាក់ៗ។

ស្ត្រីចូលរួមក្នុងនាមជាអ្នកទទួលអត្ថប្រយោជន៍ ច្រើនជាងជាអ្នកចូលរួមដ៏សកម្ម។

ទាក់ទងនឹងល័ក្ខខ័ណ្ឌនៃជីវិតប្រចាំថ្ងៃ៖ អាហារ ផ្ទះសម្បែង ចំណូល

ស្ត្រីអាចកំណត់ឃើញសេចក្ដីត្រូវការនេះដោយងាយ។

អាចឆ្លើយតបបានតាមរយៈទុនចូលផ្នែកសម្ភារៈជាក់លាក់។

តាមធម្មតា ច្រើនតែអាចឆ្លើយតបបាន ដោយមិនចាំបាច់ផ្លាស់ប្តូរតួនាទី និងទំនាក់ទំនងផ្នែកយេនឌ័រ បែបប្រពៃណី

## សេចក្ដីត្រូវការជាយុទ្ធសាស្ត្រ

ច្រើនតែមានរយៈពេលវែង។

ជាសេចក្ដីត្រូវការដែលស្ត្រីភាគច្រើនមានដូចៗគ្នា។

ស្ត្រីចូលរួមក្នុងនាមជាភ្នាក់ងារ ឬជួយជម្រុញស្ត្រីឲ្យក្លាយជាភ្នាក់ងារ។

ទាក់ទងនឹងទីតាំងចាញ់ប្រៀប ភាពតូចទាប កង្វះខាតធនធាន និងការអប់រំ ភាពងាយរងគ្រោះចំពោះភាពក្រីក្រ និងអំពើហិង្សារបស់ស្ត្រី នៅក្នុងសង្គម។

ស្ត្រីមិនអាចកំណត់ឃើញដោយងាយ។

អាចឆ្លើយតបបានតាមរយៈការលើកកំពស់ការយល់ដឹងផ្នែកយេនឌ័រ ការបង្កើនការផ្តល់តម្លៃចំពោះខ្លួនឯង និងទំនុកចិត្តលើខ្លួនឯងរបស់ស្ត្រី ការអប់រំ និងការបណ្តុះបណ្តាលជំនាញ ការតស៊ូមតិផ្នែកនយោបាយ និងការផ្តល់អំណាច។

អាចផ្តល់អំណាចដល់ស្ត្រី និងប្រែក្លាយទំនាក់ទំនងផ្នែកយេនឌ័រ

# ការធ្វើផែនការផ្នែកយេនឌ័រ

- ការរកឃើញរបស់ការវិភាគផ្នែកយេនឌ័រ និងការប៉ាន់ប្រមាណសេចក្តីត្រូវការផ្នែកយេនឌ័រ គួរត្រូវបានប្រើប្រាស់ដើម្បីផ្តល់ព័ត៌មានដល់**ការធ្វើផែនការ**យុទ្ធសាស្ត្ររបស់គ្រប់គម្រោងអន្តរាគមន៍។
- **ការធ្វើផែនការផ្នែកយេនឌ័រ** ផ្តោតទៅដោយការបង្កើតយុទ្ធសាស្ត្រ ដែលពិពណ៌នាអំពីរបៀបដើម្បីលើកកំពស់សមភាពយេនឌ័រ នៅក្នុងសកម្មភាពគម្រោង តាមរយៈវិធានការជាក់លាក់ និងការរៀបចំផ្នែកស្ថាប័នដូចជា៖
  - ប្តេជ្ញាឲ្យមានតុល្យភាពនៃតំណាងរបស់ស្ត្រី និងបុរស នៅក្នុងសកម្មភាពគម្រោង
  - ធានាឲ្យមានធនធាន និងជំនាញការគ្រប់គ្រាន់។

# សកម្មភាពដែលផ្តោត ជាក់លាក់ទៅលើយេនឌ័រ

# ការផ្តល់អំណាចដល់ស្ត្រី និងការបញ្ជ្រាប ការយល់ដឹងដល់សង្គម






# ការផ្តល់អំណាចផ្នែកយេនឌ័រ

គឺជាដំណើរការនៃការកសាងមនុស្ស ពោលគឺស្ត្រី និងបុរស ឲ្យគ្រប់គ្រងលើជីវិតរបស់ខ្លួន ទទួលបានជំនាញ កសាងទំនុកចិត្ត ដោះស្រាយបញ្ហា និងអភិវឌ្ឍស្វ័យពឹងផ្អែក

ការផ្តល់អំណាចផ្នែកយេនឌ័រ **ជួយជម្រុញសមត្ថភាព របស់ក្រុមដែលកាលពីមុនធ្លាប់តែស្ថិតនៅក្នុងទីតាំងទន់ ខ្សោយ** (ឧទាហរណ៍ ស្ត្រី ឬអ្នកមានពិការភាព) **ដើម្បីឲ្យ អាចត្រៀមខ្លួនបានកាន់តែប្រសើរ និងមានសមត្ថភាព ចូលរួមនៅក្នុងការសម្រេចចិត្ត**ដែលជះឥទ្ធិពលលើរូបពួក គេ និងសហគមន៍។

# ការផ្តល់អំណាចដល់ស្ត្រី ដើរតួនាទីយ៉ាងចាំបាច់នៅក្នុងការកាត់បន្ថយវិសមភាពយេនឌ័រ

## ទំនាក់ទំនង

↓

សេចក្តីត្រូវការជាយុទ្ធសាស្ត្រផ្នែកយេនឌ័រ ដែលចាំបាច់ត្រូវឆ្លើយតប។

# វត្តមាន និងការចូលរួមៈ មានគេមើលឃើញ និយាយច្រើន សកម្ម នឹងមានទំនុកចិត្តលើខ្លួនឯង






# ភាពស្ងាត់ស្ងៀមមិនមែនជាជម្រើសនោះទេ...



ភាពស្ងាត់ស្ងៀមជាអ្វីដែល
យើងទាំងអស់ខ្លាច។
សម្លេង ជួយឲ្យយើងមាន
តម្លៃ ប៉ុន្តែភាពស្ងាត់ស្ងៀម
មានទំហំធំល្វឹងល្វើយ។
ខ្លួនគាត់ផ្ទាល់មិនមានមុខ
មាត់។

អេមីលី ឌីខេនសិន

# ៥ ការបញ្រ្ជាបយេនឌ័រ ដើម្បីឲ្យមានការផ្លាស់ប្តូរផ្នត់គំនិតសង្គម

- បង្ហាញនូវការយល់ដឹងអំពីវិសមភាពយេនឌ័រ៖ អំពើហិង្សាផ្អែកយេនឌ័រ/ការរើសអើងផ្អែកយេនឌ័រ
- បំបែកផ្នត់គំនិតសង្គមផ្អែកយេនឌ័រ
- ការផ្លាស់ប្តូរផ្នត់គំនិតសង្គម និងសហាគមន៍អំពីយេនឌ័រ

**តាមវិធីណា** → ការអភិវឌ្ឍយុទ្ធសាស្រ្តទាក់ទងនឹងការធ្វើឲ្យសង្គមមើលឃើញ និងការផ្សព្វផ្សាយទិន្នន័យ និងព័ត៌មានដែលពាក់ព័ន្ធ និងការធ្វើការងារដើម្បីសាងការទទួលស្គាល់របស់សង្គមចំពោះការចូលរួមវិភាគទានរបស់ស្ត្រីនៅក្នុងសង្គម

# ការមើលឃើញ និង ការទទួលស្គាល់





# ការមើលឃើញ និងការទទួលស្គាល់៖ ស្ត្រីជនជាតិដើមភាគតិច





# ធ្វើឲ្យអ្វីដែលគេមើលមិនឃើញ ក្លាយជាអ្វីដែលគេមើលឃើញ

វិថីជីវិតពិតរបស់ស្រ្តីកម្ពុជាជាច្រើនបានបំបែកតួនាទីបែបប្រពៃណី និងចោទសួរទៅលើផ្នត់គំនិតសង្គមអំពីយេនឌ័រ